**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :០៨១/០០៤/២០០៤

ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០០៤

**សេចក្តីសំរេច**

លេខ:០៥៩/០០១/២០០៤ កបធ,ច

ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ១០៧ រស ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាព នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយប្រធានរដ្ឋសភាស្តីទីជាការស្របនិងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា នៅក្នុងគ្រប់ជំពូក និងប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ពុំមានបទបញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទបញ្ញត្តិនៃប្រការ ៥១ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្ដីពីការជ្រើសតាំងប្រធានបណ្ដោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំ ។ បទបញ្ញត្តិនេះ ជាប្រការមួយមានការលំបាកក្នុងការអនុវត្តន៍ជាក់ស្តែង ហើយមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ។

**សំរេច**

**មាត្រា១**~បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មាន ១៧ ជំពូក និង ៨៣ ប្រការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថាស្រប នឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥១ ដែលមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ។

**មាត្រា២**~សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តន៍ទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**